# ប្រទេសកម្ពុជា

ឆ្នាំអាក្រក់សំរាប់សេរីភាពសារពតមាន។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលមានទំលាប់ចាត់ទុកអ្នកកាសែតជា "អ្នកឆ្កុះកង្កែប" បានវាយប្រហារដោយពាក្យសំដី ដែលមានលក្ខណៈរិះគន់ខ្លាំងក្លាបំផុត។ លោកប្រមុខរដ្ឋាភិបាល បានធ្វើទុក្ខបុកម្នេញអ្នកយកព័តមាន ដែលធ្វើការស៊ើបអង្កេតលើកិច្ចចុះហត្ថលេខានៃកិច្ចព្រមព្រាងព្រំដែនដែល បង្កអោយមានសង្គ្រាមបា"កា ជាមួយប្រទេសវៀតណាម។ ការចាប់ខ្លួនកាលពីខែតុលា លើលោក ម"ម សុណាង់ដូ នាយកវិទ្យុមួយ ក្នុងចំណោមវិទ្យុឯករាជ្យដ៏កម្រនៅក្នុងប្រទេស បានបង្កការសង្ស័យលើចេតនារបស់រាជរដ្ឋាភិបាល។

ដោយត្រូវចោទប្រកាន់ ពីបទបរិហាកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ដោយធ្វើបទសម្ភាសជាមួយអ្នកប្រឆាំងម្នាក់ប្រចាំនៅប្រទេសបារាំង ស្តីពីបញ្ហាព្រំដែន ស្ថាបនិកវិទ្យុសម្បុកឃ្មុំ Fm 105 ត្រូវចោទប្រកាន់ពីបទ «ផ្សាយព័តមានមិនពិត» និង «បទញោះញង់ដល់ឧក្រិដ្ឋកម្ម»។

នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០០៦ លោក ម"ម សុណាង់ដូ នៅតែជាប់ពន្ធនាគារនៅឡើយ ក្នុងលក្ខខ័ណ្ឌយ៉ាប់យ៉ឺន។ បន្ទាប់ភ្លាមៗនោះ មន្ត្រីដែលស្និទ្ធនិងលោក ហ៊ុន សែន បានគំរាមចាប់ខ្លួនអ្នកឆ្លើយឆ្លងព័តមានពីររូប របស់វិទ្យុអន្តរជាតិ សម្លេងសហរដ្ឋអាមេរិក និង វិទ្យុអាស៊ីសេរី ដែលត្រូវបង្ខំចាកចេញពីប្រទេស។ នៅឆ្នាំ ២០០៥ វិទ្យុបារាំងអន្តរជាតិ ជាក់ស្តែងកម្មវិធីផ្សាយជាភាសាខ្មែរ ត្រូវបានអនុញ្ញាតអោយផ្សាយលើរលកធាតុអាកាស Fm នៅក្នុងរាជធានី។ ចំណែកឯ សារព័តមានប្រចាំថ្ងៃជាភាសាបារាំង កំបូដស័រ បានប្រារព្ធខួបដប់ឆ្នាំរបស់ខ្លួន៕